ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jan-2015, 10:32
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៩នាទី**

**សវនាការលើកទី២២៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម យូរ ឧត្តរា

ចៅក្រម ម៉ាទីន ខារ៉ុបគីន
*(Judge Martin KAROPKIN)*

ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ជា ស៊ីវហ៊ាង

លោក ម៉ាធូវ ម៉ាកាធី
*(Mr. Matthew McCARTHY)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង

លោក ស្រ៊ា រតនៈ

លោក ដេល លីសាក់ *(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

**មេធាវីការពារក្តីលោក នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក សួន វិសាល

**មេធាវីការពារក្តីលោក ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី គួច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក សំ សុគង់

លោក ឡៅ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោក យីគាំង លូ *(Mr. Yiqiang LIU)*

លោក ម៉ែហេស រ៉ៃ *(Mr. Mahesh RAI)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៩:០៩:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

នៅថ្ងៃនេះដោយសារលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ មានបញ្ហាសុខភាពមិនអាចចូលរួមក្នុងកិច្ចដំណើរការសវនាការបាន លោកចៅក្រម ម៉ាទីន ខារ៉ុបគីន ជំនួសលោកចៅក្រម ឡាវែន៍ រហូតដល់លោកចៅក្រម ឡាវែន៍ អាចចូលរួមសវនាការធម្មតាវិញបាន។

អង្គជំនុំជម្រះបានទទួលព័ត៌មានពីវេជ្ជបណ្ឌិតដែលទទួលពិនិត្យព្យាបាលលោក ខៀវ សំផន ថា លោក ខៀវ សំផន ត្រូវការសម្រាកព្យាបាលនៅឯមន្ទីរពេទ្យរយៈពេលប្រហែលជាប្រាំថ្ងៃទៀត។ ហេតុដូច្នេះ អង្គជំនុំជម្រះមិនធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីនៅថ្ងៃនេះបានទេ។ អង្គជំនុំជម្រះនឹងបន្តសវនាការវិញនៅថ្ងៃព្រហស្បត៍ទី១៥ ខែមករា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សូមភាគី និងសាធារណជនជ្រាប ហើយនិងសូមអញ្ជើញចូលរួមនៅក្នុងសវនាការតាមការកំណត់នេះ។ ក្នុងករណីអង្គជំនុំជម្រះទទួលបានព័ត៌មានបន្ថែមទៀតពីលោក ខៀវ សំផន មិនអាចចូលរួមសវនាការបាននៅថ្ងៃព្រហស្បត៍ទី១៥ ខែមករា ឆ្នាំ២០១៥ ខាងមុខនេះទេ អង្គជំនុំជម្រះនឹងផ្ដល់ព័ត៌មាននេះជូនទៅដល់ភាគី និងអង្គភាពរដ្ឋបាលដែលមានភារកិច្ចពាក់ព័ន្ធតាមរយៈអេឡិចត្រូនិក។ បើមិនដូច្នោះទេ អង្គជំនុំជម្រះរំពឹងថា ភាគីទាំងអស់ និងបុគ្គលដែលគាំទ្រទាំងអស់នឹងមានវត្តមាននៅថ្ងៃសវនាការថ្ងៃព្រហស្បត៍ទី១៥ ខែមករា ឆ្នាំ២០១៥ ដើម្បីបន្តកិច្ចដំណើរការសវនាការជាមួយនឹងសាក្សីដែលមានរហស្សនាម 2-TCW-936 និងដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-296។ ហើយថ្ងៃសវនាការលើកទៅធ្វើនៅថ្ងៃព្រហស្បត៍ទី១៥ ខែមករា ឆ្នាំ២០១៥ ដោយសារមូលហេតុគ្រូពេទ្យបានផ្ដល់ដំបូន្មានថា លោក ខៀវ សំផន ត្រូវទទួលការសម្រាកព្យាបាលនៅឯមន្ទីរពេទ្យរយៈពេលប្រហែលជាប្រាំថ្ងៃ ចាប់ពីថ្ងៃនេះទៅ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សី TCW-936 ត្រឡប់ទៅកាន់លំនៅដ្ឋានវិញចុះ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមក្នុងសវនាការ ដើម្បីផ្ដល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃទី -- ថ្ងៃព្រហស្បត៍ទី១៥ ខែមករា ឆ្នាំ២០១៥ ដោយឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា ត្រឡប់

ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមនូវសវនាការក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃព្រហស្បត៍ទី១៥ ខែមករា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ៩:១៣ នាទី)*